MEDIA ADVISORY

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

# កម្ពុជា៖ អ្នកជំនាញការ អ.ស.ប នឹងបំពេញបេសកកម្មថ្មីមួយ ដោយផ្តោតលើសិទ្ធិកុមារ

ហ្សឺណែវ/ភ្នំពេញ៖ (២ សីហា ២០១៧) អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្សនៅកម្ពុជា អ្នកស្រី រ៉ូណា ស្មីត នឹងបំពេញទស្សនកិច្ចលើកទីបួនរបស់អ្នកស្រីមកកាន់ប្រទេសកម្ពុជា ចាប់ពីថ្ងៃទី០៨ ដល់ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ ដើម្បីពិនិត្យមើលសិទ្ធិកុមារ និងស្ថានភាពសិទ្ធិមនុស្សទូទៅ។

" អ្នកស្រីបានកត់សម្គាល់ថា "នៅក្នុងដំណើរបេសកកម្មរបស់ខ្ញុំលើកនេះ ខ្ញុំនឹងផ្តោតលើសិទ្ធិកុមារដែលជាផ្នែកមួយនៃការងារដែលខ្ញុំកំពុងធ្វើលើវិស័យនៃការរើសអើង និងក្រុមដែលងាយរងគ្រោះ"។

"ខ្ញុំមានបំណងស្វែងយល់ជាពិសេសអំពីការជួញដូរ និងកេងប្រវ័ញ្ចលើកុមារ រួមទាំង គោលជំហរក្នុងការមើលថែកុមារ។

នៅក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចរយៈពេល ១០ ថ្ងៃរបស់អ្នកស្រី អ្នកជំនាញការរូបនេះនឹងជួបប្រជុំជាមួយក្រុម និងមន្ត្រីជាច្រើន រួមមាន សមាជិកជាន់ខ្ពស់នៃរាជរដ្ឋាភិបាល តំណាងសង្គមស៊ីវិល និងសមាជិកនៃសហគមន៍ការទូត។

អ្នករាយការណ៍ពិសេស អ.ស.ប ធ្វើទស្សនកិច្ចជាទៀងទាត់មកកាន់ប្រទេសកម្ពុជា និងធ្វើរបាយការណ៍ប្រចាំឆ្នាំទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស ដែលក្រុមប្រឹក្សានេះបានតែងតាំងអ្នកស្រីនៅក្នុងខែមីនាឆ្នាំ២០១៥។ អ្នកស្រីនឹងបង្ហាញរបាយការណ៍បន្ទាប់របស់អ្នកស្រីទៅក្រុមប្រឹក្សានេះនៅក្នុងខែកញ្ញា ឆ្នាំ២០១៧ ចំណែកឯរបាយការណ៍ស្តីពីបេសកកម្មលើកនេះ នឹងត្រូវបង្ហាញនៅខែកញ្ញា ឆ្នាំ២០១៨។

អ្នករាយការណ៍ពិសេសនឹងធ្វើ**សន្និសីទសារព័ត៌មាន** ដើម្បីពិភាក្សាអំពីការរកឃើញជំហ៊ានដំបូងនៃដំណើរទស្សនកិច្ចរបស់អ្នកស្រី នៅថ្ងៃសុក្រ ទី១៨ ខែសីហា នៅវេលាម៉ោង១៥:00 ម៉ោងក្នុងស្រុក នៅការិយាល័យសិទ្ធិមនុស្ស អ.ស.ប (ការិយាល័យ OHCHR) ដែលមានអសយដ្ឋានផ្ទះលេខ៤ ផ្លូវ២៧១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ។ សន្និសីទកាសែតនេះ អនុញ្ញាតឲ្យចូលសម្រាប់តែអ្នកសារព័ត៌មានប៉ុណ្ណោះ។

ចប់

***សាស្ត្រាចារ្យ រ៉ូណា ស្មីត*** *(ចក្រភពអង់គ្លេស) ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងក្នុងខែមីនា ឆ្នាំ ២០១៥ ជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ ក្នុងនាមជាអ្នករាយការណ៍ពិសេស អ្នកស្រី គឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ដែលជាស្ថាប័នធំបំផុតមួយរបស់អ្នកជំនាញការឯករាជ្យ នៅក្នុងប្រព័ន្ធសិទ្ធិមនុស្ស អ.ស.ប) គឺជាឈ្មោះទូទៅមួយនៃយន្តការឯករាជ្យ ឃ្លាំមើល និងស្វែងរកការពិត របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ អ្នកកាន់អណត្តិរបស់នីតិវិធី*

Office of the High Commissioner for Human Rights
Palais des Nations
CH-1211 Geneva 10
Switzerland

www.ohchr.org
Email: press-info@ohchr.org
Tel: +41 22 917 9310
Tel: +41 22 917 9383

*ពិសេស ជាអ្នកជំនាញការសិទ្ធិមនុស្សឯករាជ្យ ដែលតែតាំងដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស ដើម្បីដោះស្រាយទាំងស្ថានភាពជាក់លាក់នៃប្រទេសនីមួយៗ ទាំងបញ្ហាតាមវិស័យមួយៗ នៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ ពួកគេមិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ។ ពួកគេបម្រើការក្នុងសមត្ថភាពបុគ្គលរបស់ពួកគេផ្ទាល់ និងមិនទទួលប្រាក់បៀវត្សរ៍ពីការងាររបស់ខ្លួនឡើយ។*

*សូមឆែកមើលរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីកម្ពុជា។*

*សិទ្ធិមនុស្ស អ.ស.ប គេហទំព័រប្រទេស – កម្ពុជា*

*សម្រាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ**សូមទាក់ទងមក លោក ម៉ាន់ សុវណ្ណា (Mr. Sovanna Mann) តាមរយៈទូរស័ព្ទលេខ (+៨៥៥ ២៣ ៩៩៣ ៥៩០/៩១ លេខភ្ជាប់បន្ត៖ Ext: ២០៨ ឬ អ៊ីម៉ែល* smann@ohchr.org)

សម្រាប់**ការសាកសួរព័ត៌មាន** អំពីអ្នកជំនាញការឯករាជ្យដទៃទៀតរបស់ អ.ស.ប សូមទាក់ទង៖
លោក សាប៊ៀរ សេឡាយ៉ា (Xabier Celaya) អង្គភាពប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន OHCHR តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣ ឬ អ៊ីម៉ែល xcelaya@ohchr.org)

**អ្នកអាចរកបាននូវសេចក្តីប្រកាសព័ត៌មាននេះតាមអនឡាញបាន**

តើលោក អ្នក ខ្វល់ខ្វាយអំពីពិភពលោកដែលយើងរស់នៅឬទេ? អញ្ចឹង យើង**ត្រូវក្រោកឈរដើម្បីសិទ្ធិនរណាម្នាក់នៅថ្ងៃនេះ** #Standup4humanrights និងចូលទៅកាន់ទំព័រវេបសាយ៖
http://www.standup4humanrights.org